# របាយការណ៍ជួញដូរមនុស្ស ឆ្នាំ ២០១៣

# របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក - ប្រទេសកម្ពុជា

កម្ពុជាគឺជាប្រទេសប្រភព ប្រទេសឆ្លងកាត់ និងជាប្រទេសគោលដៅសំរាប់បុរស ស្ត្រី និងកុមារ ដែលរងគ្រោះដោយការបង្ខំអោយធ្វើពលកម្ម និងការជួញដូរផ្លូវភេទ។ បុរស ស្ត្រី និង កុមារកម្ពុជា ធ្វើបំលាស់ទីទៅកាន់បណ្តាប្រទេសនៅក្នុងតំបន់ ជាពិសេសប្រទេសថៃ និងប្រទេសម៉ាឡេស៊ី តែក៏មានទៅប្រទេសសឹង្ហបូរី វៀតណាម និងកូរ៉េខាងត្បូងផងដែរ ដើម្បីរកការងារធ្វើនៅតាមរោងចក្រ អាហារដ្ឋាន ឬឧស្សាហកម្មផ្សេងទៀត តែមានច្រើននាក់ត្រូវរងគ្រោះដោយការជួញដូរផ្លូវភេទ ទាសភាពនៅផ្ទះ ទាសភាពបំណុលដោះមិនរួច ឬស្ថានភាពត្រូវបានគេបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងរក្នុងទូកនេសាទ សំណង់ កន្លែងកែច្នៃម្ហូបអាហារ និងកសិឧស្សាហកម្ម ។ ស្ត្រីនិងកុមារវៀតណាម ដែលមានច្រើនរងគ្រោះដោយទាសភាពបំណុល (Debt bondage) ត្រូវបានគេនាំយកមកប្រទេសកម្ពុជា ហើយត្រូវបានបង្ខំអោយបំរើផ្លូវភេទ។ មន្ត្រីពុករលួយនៅប្រទេសកម្ពុជា និងប្រទេសថៃជួយសំរួលដល់ការនាំជនរងគ្រោះឆ្លងព្រំដែន។ លើសពីនេះទៀត ជនរងគ្រោះ ដោយការជួញដូរក្នុងចំនួននិងមានអត្តសញ្ញាដែលគេមិនដឹង ស្ថិតក្នុងចំណោមជនអន្តោប្រវេសន៍យ៉ាងច្រើន ដែលត្រូវបានចាប់បញ្ជូនមកពីប្រទេសថៃវិញ ក្នុងមួយឆ្នាំៗ។ ក្នុងឆ្នាំរបាយការណ៍នេះ មានបុរសកម្ពុជាត្រូវ បានបង្ខំអោយធ្វើការក្នុងទូកនេសាទដែលដោតទង់ជាតិថៃ។ អង្គការមួយដែលធ្វើការជួយជនរងគ្រោះនៅ កម្ពុជា បានរាយការណ៍ពីកំណើននៃការចាប់បញ្ជូនមកវិញនូវជនរងគ្រោះខ្មែរក្នុងឧស្សាហកម្មនេសាទរបស់ ថៃ ក្នុងរយៈពេល ២ ខែដំបូងនៃឆ្នាំ២០១៣។ ជនរងគ្រោះខ្មែរដែលបានគេចខ្លួនរួចពីជនជួញដូរលើរូបគេនៅ ក្នុងឧស្សាហកម្មនេសាទ ត្រូវបានគេជួបប្រទះនៅប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ម៉ូរីតេស ហ្វីជី សេណេហ្កាល់ និងអាហ្វ្រិកខាងត្បូង។ បុរសទាំងនោះបាននិយាយថា ខ្លួនគេត្រូវបានបោកបញ្ឆោតដោយថៅកែទូកនេសាទ

ថៃ ទាក់ទងនឹងរយៈពេលត្រូវធ្វើការ និងប្រាក់ឈ្នួល។ បុរសកម្ពុជាខ្លះថែមទាំងបានប្រាប់ពីការធ្វើបាបយ៉ាងធ្ងន់ធ្ងរដោយមេការថៃនៅលើទូក ហើយត្រូវបានបង្ខំអោយនៅលើទូករហូតដល់រយៈពេល ២ ឆ្នាំ។

ការមិនយល់ពីកាតព្វកិច្ច ការមិនចេះអានកិច្ចព្រមព្រៀង ឬគ្មានលុយបង់ថ្លៃក្រដាសស្នាម និងការគ្មានការគ្រប់គ្រងលើច្បាប់ទំលាប់អោយបានគ្រប់គ្រាន់ពីសំណាក់រដ្ឋាភិបាលបានធ្វើអោយកម្មករចំណាកស្រុកកម្ពុជាខ្លះងាយរងនឹងការបង្ខំអោយធ្វើការ និងបំណុលទាសភាព នៅក្នុងប្រទេសគោលដៅ ពិសេសនៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ។ ពលករទាំងនោះបាននិយាយពីការដែលថៅកែក្នុងប្រទេសដែលគេទៅដល់នោះ មិនព្រមផ្តល់សំណៅនៃកិច្ចសន្យាការងារ ឬដកហូតលិខិតឆ្លងដែន។ ទីភ្នាក់ងារជ្រើសរើសពលករត្រូវបានរាយការណ៍មកថា បានកែអត្តសញ្ញាណប័ណ្ណស្របច្បាប់ និងឯកសារបញ្ជាក់អាយុ ដើម្បីអាចជ្រើសរើសពលករជាកុមារដោយខុសច្បាប់បាន។ ការហាមប្រាមលើការនាំស្ត្រីខ្មែរអោយទៅបំរើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ីបានបណ្តាលអោយទីភ្នាក់ងារជ្រើសរើសពលករជាច្រើនបិទទ្វារ។ ក្នុងករណីជាច្រើនទីភ្នាក់ងារជ្រើសរើសពលករទាំងនេះគឺគ្រាន់តែជាតំណភ្ជាប់រវាងពលករខ្មែរនៅប្រទេសម៉ាឡេស៊ី និងគ្រួសាររបស់គេនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ដូច្នេះ ការហាមប្រាមនេះបានបង្កើតអោយមានការពិបាកក្នុងការកំណត់ចំនួនពលករដែលកំពុងស្ថិតនៅប្រទេសម៉ាឡេស៊ី ហើយបង្កើនការប្រឈមរបស់គេជាមួយនឹងការកេងប្រវ័ញ្ច និងការធ្វើបាប។ ទោះបីជាមានការហាមប្រាមជាបន្តក្តី ក៏ស្ត្រី និងកុមារីដែលស្វែងរកការងារធ្វើនៅតែបន្តធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី ដោយតាមសេចក្តីរាយការណ៍គឺតាមរយៈការប្រើទិដ្ឋាការទេសចរ។ មានខ្លះ បានក្លាយជាជនរងគ្រោះបែបទាសភាពនៅក្នុងផ្ទះ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជនរងគ្រោះកម្ពុជាខ្លះបានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ីដោយឆ្លងកាត់ប្រទេសថៃ ហើយមានខ្លះទៀតដោយមានជនរងគ្រោះវៀតណាមខ្លះផង ត្រូវបាននាំឆ្លងកាត់ប្រទេសកម្ពុជាដោយក្រុមឧក្រិដ្ឋជន មុនពេលត្រូវបានគេកេងប្រវ័ញ្ចទៅលើនៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។

នៅប្រទេសកម្ពុជា កុមារនៅក្នុងគ្រួសារក្រីក្រងាយរងគ្រោះខ្លាំងដោយសារការបង្ខំអោយធ្វើពលកម្ម រួមទាំងការងារបំរើដូចទាសករនៅតាមផ្ទះ ហើយត្រូវបានឪពុកម្តាយបញ្ជូនអោយដើរសុំទានតាមផ្លូវ នៅប្រទេសថៃ។ កុមារកម្ពុជាថែមទាំងត្រូវបានគេនាំយកទៅប្រទេសវៀតណាមដើម្បីបង្ខំអោយធ្វើពលកម្ម និងដើរសុំទាន។ តំបន់ពេស្យាចារស្វាយប៉ាក នៅក្រៅក្រុងភ្នំពេញ ដែលនៅទីនោះ មានការប្រកបមុខរបរកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅតែបន្តសកម្មភាពដដែល ទោះបីជានគរបាលបានខិតខំបិទជាច្រើនលើកច្រើនសារហើយក៏ដោយ។

នៅក្នុងប្រទេស ស្ត្រីនិងកុមារវៀតណាមនិងកម្ពុជាបានធ្វើដំណើរឬត្រូវបានគេនាំមកពីតំបន់ជនបទមកក្រុងភ្នំពេញ សៀមរាប ប៉ោយប៉ែត កោះកុង និង ទីក្រុងព្រះសីហនុ ដែលនៅទីនោះ ពួកគេរងការជួញដូរនៅតាមផ្ទះបន និងកាន់តែច្រើនឡើង នៅតាមកន្លែងដូចជាហាងបៀហ្គាដិន កន្លែងម៉ាសា កន្លែងធ្វើខ្លួន ហាងខារ៉ាអូខេ និងកន្លែងមិនមែនរកស៊ីដទៃទៀត។ នគរបាល និងអង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា អ្នកប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារបានប្រើល្បិចថ្មីទៀត ដើម្បីគេចពីការជាប់ទោស។ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារឥឡូវច្រើនមានឡើងនៅតាមកន្លែងផ្សេងក្រៅពីផ្ទះបន ដោយជាញឹកញាប់ តាមរយៈការប្រើមេអណ្តើកបន្ថែម ថ្វីបើជនប្រព្រឹត្តការជួញដូរនៅតាមកន្លែងធម្មតាបន្តធ្វើការសំរបសំរួលដល់ការកេងប្រវ័ញ្ចប្រភេទនេះក្តី។ ការជួញដូរផ្លូវភេទលើកុមារអាយុក្រោម ១៥ ឆ្នាំ ដែលពីមុនធ្វើដោយមិនសូវលាក់លៀមឥឡូវកាន់តែមានលក្ខណៈលាក់បាំងច្រើន។ ការលក់កុមារី និងនារីព្រហ្មចារីនៅតែជាបញ្ហាធ្ងន់ធ្ងរនៅប្រទេសកម្ពុជា។ បុរសកម្ពុជាគឺជាប្រភពធំបំផុតនៃតំរូវការពេស្យាចារកុមារ តែក៏មាន ចំនួនច្រើនគួរសមនៃបុរសធ្វើដំណើរមកពីសហរដ្ឋអាមេរិក និងអឺរ៉ុប ព្រមទាំងប្រទេសអាស៊ីដទៃទៀត មកប្រទេសកម្ពុជា ជាទេសចរផ្លូវភេទលើកុមារផងដែរ។

រដ្ឋាភិបាលកម្ពុជាមិនបានគោរពបានពេញលេញតាមបទដ្ឋានអប្បបរិមា សំរាប់ការបំបាត់ការជួញដូរមនុស្សទេ ។ ទោះជាយ៉ាងណាក្តី ក៏រដ្ឋាភិបាលកំពុងតែខិតខំច្រើនគួរសមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញ

ដូរមនុស្ស ។ ទោះបីជាមានវិធានការទាំងនេះក្តី ក៏រដ្ឋាភិបាលមិនបានសំរេចបានភាពជឿនលឿនទៅមុខទេក្នុងការចាប់ជនប្រព្រឹត្តការជួញដូរមនុស្ស និងទេសចរផ្លូវភេទលើកុមារអោយទទួលទោសដោយសារការកាត់ទោស និងការដាក់ទោសមិនគ្រប់គ្រាន់ ហើយការខិតខំរបស់រដ្ឋាភិបាលក្នុងការការពារជនរងគ្រោះនៅតែមានភាពមិនគ្រប់គ្រាន់ដដែល។ រដ្ឋាភិបាលបានកាត់ទោស និងដាក់ទោសជនប្រព្រឹត្តការជួញដូរ ហើយបានរកឃើញជនរងគ្រោះតិចជាងកាលពីឆ្នាំកន្លងទៅ។ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលមិនបានខិតខំដោះស្រាយបញ្ហាអំពើពុករលួយទាក់ទងនឹងការជួញដូរទេ ហើយការផ្សំគំនិតរបស់មន្ត្រីរដ្ឋាភិបាលបានជួយធ្វើអោយមានបរិយាកាសនិទណ្ឌភាពសំរាប់ជនប្រព្រឹត្តការជួញដូរ ហើយនិងការធ្វើអោយជនរងគ្រោះមិនអាចទទួលបានយុត្តិធម៌។ រដ្ឋាភិបាលបានតាក់តែងនិតិវិធីប្រតិបត្តិដើម្បីជួយបុរសរងគ្រោះដោយការជួញដូរ តែមិនបានផ្តល់ការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះទាំងនោះទេ នៅក្នុងអំឡុងឆ្នាំនៃរបាយការណ៍។ រដ្ឋាភិបាលបន្តខ្វះនិតិវិធីជាប្រព័ន្ធសំរាប់អោយបេសកកម្មទូតរបស់ខ្លួននៅបរទេសជួយជនរងគ្រោះដោយសារការជួញដូរ។ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការមិនអនុញ្ញាតអោយមានប្រតិបត្តិការសំងាត់ប្រឆាំងនឹងការជួញដូរមនុស្សគឺជាឧបសគ្គដល់ការអនុវត្តច្បាប់ ដើម្បីតាមដានលើករណីអោយបានជោគជ័យហើយការខកខានរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាដែលមិនធ្វើអោយជនរងគ្រោះមានចិត្តចង់ចូលរួមនៅក្នុងការស៊ើបអង្កេត និងការកាត់ទោសក៏បង្ករអោយមានឧបសគ្គនេះដែរ។ រដ្ឋាភិបាលបានកាត់ទោស និងដាក់ទោសលើបុគ្គលិកនៃក្រុមហ៊ុនជ្រើសរើសពលករមួយដែលបានធ្វើការជួញដូរកំលាំងពលកម្ម។ ដោយសាររដ្ឋាភិបាលមិនបានបង្ហាញភស្តុតាងនៃការបង្កើនការខិតខំជារួមដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស ក្នុងពេលមួយឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាត្រូវបានដាក់ចូលក្នុងចំណាត់ថ្នាក់លេខ ២ ក្នុងបញ្ជីតាមដាន។

**អនុសាសន៍សំរាប់ប្រទេសកម្ពុជា៖** បង្កើនការខិតខំក្នុងការស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស និងដាក់ទណ្ឌកម្មចំពោះជនល្មើសក្នុងការជួញដូរ ទាំងអ្នកជួញដូរពលករ ទាំងអ្នកជួញដូរផ្លូវភេទ ចេញប្រកាសអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់ នៅក្នុងការអនុវត្តច្បាប់ប្រឆាំងការ

ជួញដូរ កែលំអការខិតខំក្នុងការស៊ើបអង្កេតនិងកាត់ទោសមន្ត្រីរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធក្នុងការជួញដូរមនុស្ស  ចេញវិធានការតឹងរឹងក្នុងការតាមដាន និងអនុវត្តដើម្បីគ្រប់គ្រងអោយបានល្អនូវការជ្រើសរើសពលករ ការរកការងារអោយ និងការការពារពលករចំណាកស្រុកនៅបរទេស ដាក់ទោសព្រហ្មទណ្ឌលើក្រុមហ៊ុនជ្រើសរើសពលករ ដែលប្រព្រឹត្តខុសច្បាប់ក្នុងពេលជ្រើសរើសពលករ ដូចជាទាសភាពបំណុល ការឃុំពលករទុកមួយកន្លែងក្នុងអំឡុងពេលរៀនសូត្រមុនពេលចេញដំណើរ ហើយនិងការជ្រើសរើសពលករអាយុក្រោម ១៨ ឆ្នាំ។ ធ្វើអោយអាជ្ញាធរអនុវត្តច្បាប់ និងអ្នកចេញគោលនយោបាយយកចិត្តទុកដាក់ចំពោះការមានច្រើនឡើងនៃការជួញដូរបុរសពេញវ័យ ជាពិសេសក្នុងផ្នែកនេសាទ ហើយជួយអោយបុរសរងគ្រោះអាចទទួលបានសេវាច្រើន សំរួលនិតិវិធីសំរាប់ធ្វើការរាយការណ៍ និងឆ្លើយតបទៅនឹងករណីដែលជនរងគ្រោះត្រូវបានរកឃើញនៅតាមប្រទេសដែលកម្ពុជាគ្មានតំណាងទូតនៅក្នុងនោះ ។ កែប្រែអនុក្រិត្យលេខ ១៩០ ដោយបញ្ចូលបញ្ញាតិច្បាស់លាស់ ប្រកបដោយតំលាភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីការពារពលករចំណាកស្រុក បង្កើនការខិតខំធ្វើអោយដំណើរតុលាការមានប្រសិទ្ធភាពច្រើន និងគិតគូរពីសេចក្តីត្រូវការនិងផលប្រយោជន៍របស់ជនរងគ្រោះដោយការជួញដូរ បង្កើតអោយមានការបញ្ជាក់ការការពារសាក្សី ជាពិសេសសំរាប់ជនងរងគ្រោះដោយការជួញដូរ បង្កើនការខិតខំក្នុងការរកមើលជនរងគ្រោះដោយការជួញដូរក្នុងចំណោមក្រុមមនុស្សងាយរងគ្រោះ ដូចជាកុមារ និងពលករចំណាកស្រុកកម្ពុជាដែលទៅឬមកពីធ្វើការនៅប្រទេសដទៃ កំណត់ពិធីសារក្នុងការកំណត់អត្តសញ្ញាណនៃជនរងគ្រោះនៅទូទាំងប្រទេស បង្កើនការបញ្ជូនដោយរដ្ឋាភិបាលនូវជនរងគ្រោះដោយការជួញដូរទៅអោយអង្គការមិនមែនរដ្ឋាភិបាល ដោយបន្ថែមការឧបត្ថម្ភ និងសេវា ដែលរួមមានជំនួយផ្លូវច្បាប់ ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម និងកម្មវិធីធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ បង្កើតនិតិវិធីជាប្រព័ន្ធដើម្បីជួយជនរងគ្រោះខ្មែរតាមរយៈបេសកកម្មទូតនៅបរទេស ប្រហែលដោយតែងតាំងអនុព័ន្ធការងារដែលធ្វើការច្បាស់លាស់នៅតាមប្រទេសដែលមានពលករខ្មែរច្រើន។កែលំអការសហការ និងសហប្រតិបត្តិការជាអន្តរទីភ្នាក់ងាររវាងនគរបាល មន្ត្រីតុលាការ និងបុគ្គលិកដទៃទៀតរបស់រដ្ឋ លើករណីជួញដូរ និងដំណើរការនៃការបញ្ជូនជនរងគ្រោះ ហើយបន្តប្រកាស

អោយមានយុទ្ធនាការលើកកំពស់ការយល់ដឹងរបស់សាធារណជន ដើម្បីកាត់បន្ថយតំរូវការលើការជួញដូរផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ របស់មនុស្សនៅក្នុងស្រុក និងជនបរទេស។

## ការនាំខ្លួនយកមកកាត់ទោស

រដ្ឋាភិបាលកម្ពុជាមិនបានបង្ហាញអោយឃើញភាពជឿនលឿនទៅមុខទេ នៅក្នុងការងារអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ ច្បាប់ដែលត្រូវបានដាក់ចេញនៅឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទមាននិយាយច្បាស់ពីបទល្មើសជួញដូរជាច្រើន ក្នុងមាត្រាចំនួន ១២ ក្នុងចំណោមមាត្រាចំនួន ៣០ ក្នុងច្បាប់នេះ។ ច្បាប់នៅកម្ពុជាហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការជួញដូរមនុស្ស ចែងពីការដាក់ទោសចំពោះបទល្មើស ដែលមានភាពម៉ឺងម៉ាត់គ្រប់គ្រាន់ និងស្របតាមទោសសំរាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដូចជាការរំលោភសេពសន្ថវៈ។ ក្នុងឆ្នាំនេះ ក្រសួងយុត្តិធម៍បាននាំមកកាត់ទោសចំនួន ៥០ ករណី ដែលបាននាំដល់ការផ្តន្ទាទោសលើ ៤៤ ករណី ។ ឆ្នាំមុន មានការកាត់ទោសចំនួន ១០២  ករណី និងការផ្តន្ទាទោសចំនួន ៦២ ករណី។ ក្នុងចំណោមករណីផ្តន្ទាទោសទាំង ៤៤ នេះ មានជនល្មើស ៥ នាក់ត្រូវបានកាត់ទោសដោយប្រើច្បាប់ប្រឆាំងការជួញដូរ ហើយជនពាក់ព័ន្ធការជួញដូរចំនួន ៣៩ នាក់ទៀតត្រូវបានកាត់ទោសក្រោមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីស្ថានទំងន់។ ភាគច្រើននៃការផ្តន្ទាទោសត្រូវបានរាយការណ៍មកថា ទាក់ទងនឹងការជួញដូរផ្លូវភេទ។ បុគ្គលិក ៤ នាក់របស់ទីភ្នាក់ងារជ្រើសរើសពលករដែលមានច្បាប់អនុញ្ញាតបានជាប់ទោសពីបទជួញដូរពលកម្ម ហើយអ្នកឯទៀតបានជាប់ទោសពីបទជួញដូរផ្លូវភេទ។ ក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលកម្ពុជាបានរៀបចំនិងបើកការបណ្តុះបណ្តាលក្រោមជំនួយរបស់ម្ចាស់អំណោយសំរាប់មន្ត្រីតុលាការ និងសមត្ថកិច្ចចំនួន ១៤០០ រូប ស្តីពីការអនុវត្តច្បាប់ប្រឆាំងការជួញដូរ តែមន្ត្រីតុលាការ និងមន្ត្រីនគរបាលខ្វះជំនាញក្នុងការកំណត់ និងកាត់ទោសករណីជួញដូរយ៉ាងច្រើន។ ពេលខ្លះ មន្ត្រីទាំងនោះបញ្ចូលជាមួយគ្នានូវការជួញដូរពលកម្មនិងការរត់ពន្ធមនុស្ស ហើយកង្វះជំនាញក្នុងការប្រមូលភស្តុតាងនាំអោយមន្ត្រីទាំងនោះពឹងផ្អែកស្ទើរតែទាំងស្រុងលើកសិណសាក្សីរបស់ជន

រងគ្រោះសំរាប់កសាងសំណុំរឿង។ ការខិតខំមិនគ្រប់គ្រាន់ដើម្បីការពារជនរងគ្រោះ ដោយរួមទាំងកង្វះការលើកទឹកចិត្តអោយជនរងគ្រោះចូលរួមក្នុងការកាត់ទោសបានធ្វើអោយពួកគេជាច្រើនមិនចង់ចូលរួម។ ជនរងគ្រោះដែលគ្រួសាររបស់គេបានទទួលសំណងនៅក្រៅតុលាការពីជនប្រព្រឹត្តការជួញដូរ ពេលខ្លះផ្លាស់ប្តូរចំលើយជាកសិណរបស់គេ ដែលជាឧបសគ្គមួយធ្វើមិនអោយដំណើរការកាត់ទោសទទួលបានជោគជ័យ។

ទោះបីជាមិនត្រូវបានហាមឃាត់ច្បាស់ដោយច្បាប់កម្ពុជាក្តី តែប្រតិបត្តិការប្រមូលភស្តុតាងសំងាត់ក្នុងករណីជួញដូរមនុស្សត្រូវបានថៅក្រមខ្មែរគិតថា ខុសច្បាប់ក្នុងប៉ុន្មានឆ្នាំនេះ។ ថ្វីបើរដ្ឋាភិបាលបានយល់ព្រមអោយមានការអង្កេតសំងាត់សំរាប់ការស៊ើបអង្កេតដទៃទៀតក្តី ដូចជាការស៊ើបអង្កេតប្រឆាំងគ្រឿងញៀន តែការយល់ព្រមបែបនេះមិនត្រូវបានផ្តល់សំរាប់ការស៊ើបអង្កេតលើករណីសង្ស័យ នៅក្រោមច្បាប់ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ ២០០៨ ឡើយ។ លើសពីនេះទៀត វិធីរបស់ជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារមានលក្ខណៈកាន់តែជឿនលឿន ហើយពិបាកតាមដាន ដែលជាការធ្វើអោយការស៊ើបអង្កេតសំងាត់និងការស៊ើបអង្កេតបង្ការជាមុនក្លាយជាការចាំបាច់សំរាប់ប្រមូលភស្តុតាងអោយបានគ្រប់គ្រាន់សំរាប់កសាងសំណុំរឿង។

អំពើពុករលួយដែលមានជាទូទៅនៅគ្រប់លំដាប់ថ្នាក់ទាំងអស់បានបន្តរាំងស្ទះដល់ការប្រឹងប្រែងប្រឆាំងការជួញដូរ ។ អ្នកសង្កេតការក្នុងស្រុកជឿថា វាជាបុព្វហេតុនៃនិទណ្ឌភាពសំរាប់ក្រុមហ៊ុនជ្រើសរើសពលករ រួមទាំងក្រុមហ៊ុនខ្លះដែលតាមសេចក្តីរាយការណ៍មកថា មានភាគហ៊ុនជាមួយមន្ត្រីរដ្ឋាភិបាល ហើយធ្វើការជ្រើសរើសពលករដោយខុសច្បាប់ ដែលជាការរួមចំណែកអោយមានការជួញដូរ។ រដ្ឋាភិបាលបានរាយការណ៍មកថា គ្មានមន្ត្រីរដ្ឋាភិបាលណាម្នាក់ត្រូវបានគេស៊ើបអង្កេតទៅលើ ត្រូវបានកាត់ទោស ឬដាក់ទោសពីបទពាក់ព័ន្ធនឹងការជួញដូរ ឬសកម្មភាពទាក់ទងនឹងការជួញដូរឡើយ។ អតីតប្រធានការិយាល័យប្រឆាំងការជួញដូរ និងការពារអនិតិជននៃនគរបាលក្រុងភ្នំពេញ ដែលត្រូវបានដាក់ទោសដោយកំបាំង

មុខ ពីបទពាក់ព័ន្ធនឹងការជួញដូរមនុស្ស កាលពីឆ្នាំកន្លងទៅ មិនត្រូវបានចាប់ខ្លួនទេ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ ហើយនៅមានសេរីភាពនៅឡើយ។

**ការការពារ** (Protection)

ស្ថាប័នរដ្ឋមួយចំនួនបានបន្តប្រើនិតិវិធីជាប្រព័ន្ធដើម្បីរកមើលជនរងគ្រោះដោយសារការជួញដូរ ហើយបញ្ជូនពួកគេទៅអោយអង្គការមិនមែនរដ្ឋាភិបាលថែរក្សា តែរដ្ឋាភិបាលមានភាពជឿនលឿនមានកំរិតនៅក្នុងការពង្រឹងនិតិវិធីទាំងនេះ និងក្នុងការធ្វើវាអោយមានលក្ខណៈឯកភាពនៅទូទាំងប្រទេស ហើយចំនួនជនរងគ្រោះដែលរកឃើញមានការថយចុះមកតិចជាងឆ្នាំទៅ។ភាគច្រើននៃសេវាផ្នែកពេទ្យ ច្បាប់ និងសេវាផ្តល់ទីជំរកត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការថែទាំដល់ជនរងគ្រោះដោយសារការរំលោភធ្វើបាបក្នុងទំរង់មួយចំនួន។ ថ្វីបើគ្មាននិតិវិធីសំរាប់អោយសមត្ថកិច្ចធ្វើការកំណត់អោយបានឆាប់នូវអត្តសញ្ញាណជនរងគ្រោះ ក្នុងចំណោមជនដែលងាយរងគ្រោះក្តី តែរដ្ឋាភិបាលបានបន្តខិតខំក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ ដោយពិគ្រោះយោបល់ជាមួយទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ។ អាជ្ញាធរបានបញ្ជូនជនរងគ្រោះដែលត្រូវបានកំណត់បានហើយទៅទីជំរករបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីអោយគេទទួលបានការថែទាំ តែមិនបានដាក់ចេញនូវគោលនយោបាយសំរាប់ការផ្ទេរការគ្រប់គ្រងជាផ្លូវការលើជនរងគ្រោះជាកុមារទេ ហើយការនេះធ្វើអោយអង្គការមិនមែនរដ្ឋាភិបាលដែលទទួលជនរងគ្រោះទាំងនេះមកថែទាំ ងាយរងនឹងការប្តឹងផ្តល់។ រដ្ឋាភិបាលក៏មានកន្លែងផ្តល់ជំរកបណ្តោះអាសន្នមួយដែរនៅក្នុងទីក្រុងភ្នំពេញ សំរាប់ស្ត្រី និងកុមារី ដែលរងគ្រោះដោយការជួញដូរ និងបទល្មើសដទៃទៀត តែអាជ្ញាធរមិនផ្តល់ជំនួយអ្វីបន្ថែមលើសនេះដល់ជនរងគ្រោះទេ។កង្វះការថែទាំរយៈពេលយូរបានធ្វើអោយជនរងគ្រោះ ពិសេសកុមាររងគ្រោះដោយការជួញដូរផ្លូវភេទ ងាយរងគ្រោះដោយការជួញដូរសារជាថ្មី។ ក្រសួងសង្គមកិច្ចបានចេញនិតិវិធីបទដ្ឋានប្រតិបត្តិស្តីពីការឧបត្ថម្ភសំរាប់សមាហរណកម្មនៃជនរងគ្រោះជាបុរស ដោយគូសបញ្ជាក់ពីនិតិវិធីសំរាប់ការពិនិត្យ និងការធ្វើសមាហរណកម្មនៃបុរស

ជាជនរងគ្រោះដោយការជួញដូរ តែការការពារសំរាប់បុរសរងគ្រោះនៅតែមិនគ្រប់គ្រាន់នៅឡើយ។ ថ្វីបើមានជនរងគ្រោះជាបុរសច្រើនក្តី ក៏នៅតែមានកង្វះកន្លែងជំរកសំរាប់ពួកគេដដែល ពីព្រោះរដ្ឋាភិបាលកម្ពុជាមិនតំរូវអោយអង្គការមិនមែនរដ្ឋាភិបាលទទួលជនរងគ្រោះជាបុរសទេ ហើយអង្គការជាច្រើនមិនព្រមទទួលពួកគេទេ។ ជនរងគ្រោះដោយការជួញដូរជាបរទេសមានលទ្ធភាពទទួលបានកន្លែងថែទាំសំរាប់ជនរងគ្រោះដូចជនរងគ្រោះដោយការជួញដូរខ្មែរដែរ តែមានកន្លែងជំរកក្នុងចំនួនមានកំរិត ដែលមានលទ្ធភាពផ្តល់ការថែទាំពិសេសដល់ជនរងគ្រោះបរទេស ដោយរួមមានទាំងការចេះភាសា និងការជួយដែលសមស្របតាមវប្បធម៌របស់គេ។

ក្រសួងសង្គមកិច្ចបានរាយការណ៍ពីការបានទទួល និងបានបញ្ជូនជនរងគ្រោះដោយការជួញដូរចំនួន ៥៧០ នាក់ទីកាន់កន្លែងផ្តល់ទីជំរក ហើយនគរបាលមូលដ្ឋានបានបញ្ជូនជនរងគ្រោះដោយការជួញដូរផ្លូវភេទចំនួន ៣៨៨ នាក់ទៅស្ថាប័នខេត្តសំរាប់ការបញ្ជូនបន្តទៅអង្គការមិនមែនរដ្ឋាភិបាល។ ចំនួនជនរងគ្រោះ ៩៥៨ នាក់ ដែលត្រូវបានរកឃើញនិងបញ្ជូនគឺជាចំនួនថយចុះពីចំនួន ១១៣១ នាក់ ដែលត្រូវបានរកឃើញនិងបញ្ជូន នៅក្នុងអំឡុងពេលនៃរបាយការណ៍មុន។ ដោយមានជំនួយពីអង្គការអន្តរជាតិមួយ ក្រសួងសង្គមកិច្ចបានបន្តដំណើរការមជ្ឈមណ្ឌលទទួលអោយស្នាក់នៅបណ្តោះអាសន្នមួយនៅប៉ោយប៉ែត ដែលនៅទីនោះក្រសួងបានទទួលជនរងគ្រោះចំនួន ២៧ នាក់ដែលរកឃើញដោយអាជ្ញាធរថៃ ហើយបានរកឃើញជនរងគ្រោះដោយការជួញដូរបន្ថែមចំនួន ៦៤ នាក់ ក្នុងចំណោមជនជាតិខ្មែរធ្វើចំណាកស្រុក ហើយដែលត្រូវបានបញ្ជូនមកពីប្រទេសថៃវិញចំនួនប្រមាណ ១០០ ០០០ នាក់  គឺថយពីចំនួនជនរងគ្រោះចំនួន ១០៤ នាក់ដែលត្រូវបានរកឃើញនៅក្នុងឆ្នាំកន្លងទៅនេះ។ ដោយសារនិតិវិធីកំណត់អត្តសញ្ញានជនរងគ្រោះនៅសងខាងព្រំដែនទាំងពីរគ្មានភាពគ្រប់គ្រាន់ ចំនួនពិតប្រាកដនៃជនរងគ្រោះដោយការជួញដូរនៅក្នុងចំណោមប្រជាជនទាំងនោះទំនងជាមានច្រើនជាងនេះច្រើន។ អង្គការមិនមែនរដ្ឋាភិបាលខ្មែរនិងបរទេសបានធ្វើមាតុភូមិនិវត្តន៍ក្រៅផ្លូវការនូវជនរងគ្រោះនៅលើទូកនេសាទថៃ ដូច្នេះចំនួនសរុបនៃជនរងគ្រោះដែលវិលត្រឡប់វិញមិនត្រូវ

បានគេដឹងទេ។ អង្គការមួយបានរាយការណ៍ថា បាននាំត្រឡប់វិញនូវជនរងគ្រោះជាបុរសចំនួន ៥១ នាក់ពីប្រទេស Mauritius ឥណ្ឌូនេស៊ី ហ្វីជី សេណេហ្កាល់ ចិន ម៉ាឡេស៊ី និងអាហ្វ្រិកខាងត្បូង ហើយបានផ្តល់ការជួយដល់រដ្ឋាភិបាលក្នុងការធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះជាបុរសចំនួន ១៧ នាក់ ពីប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ក្នុងអំឡុងពេលនៃរបាយការណ៍នេះ តែនេះគ្រាន់តែជាចំណែកតូចមួយនៃចំនួនសរុបនៃបុរសខ្មែរដែលគេជឿថា ត្រូវបានគេជួញដូរអោយធ្វើការនៅតាមទូកនេសាទ។ រដ្ឋាភិបាលគ្មាននិតិវិធីគ្រប់គ្រាន់សំរាប់សំរួលដល់ការជួយសង្គ្រោះជនរងគ្រោះពីការចាប់បង្ខំអោយធ្វើការនៅតាមទូកនេសាទ ដែលត្រូវបានគេរកឃើញនៅបរទេសឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ក្រសួងការបរទេសគ្មានអ្នកសំរាប់ទាក់ទងនិងសំរបសំរួលសំរាប់ករណីទាំងនេះទេ ហើយមិនបានឆ្លើយតបនឹងសំណើសុំជំនួយទេ ក្នុងអំឡុងឆ្នាំនៃរបាយការណ៍នេះ។

ក្នុងអំឡុងពេលនៃរបាយការណ៍មុននេះ រដ្ឋាភិបាលបានហាមប្រាមមិនអោយនារីធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ីដើម្បីបំរើការងារតាមផ្ទះជាបន្ថែមទៀត តែមិនបានធានាថា មាននិតិវិធី ឬបញ្ញាតិការពារសំរាប់ជួយនារីខ្មែរដែលកំពុងតែធ្វើការនៅប្រទេសម៉ាឡេស៊ីទេ។ ការហាមប្រាមនេះអាចជួយអោយភាពងាយរងគ្រោះរបស់នារីខ្មែរដែលបំរើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ីរឹតតែមានច្រើនថែមទៀត។ ពីព្រោះនៅពេលភាគច្រើននៃក្រុមហ៊ុនជ្រើសរើសពលករបិទ នារីដែលរងការកេងប្រវ័ញ្ចនៅប្រទេសម៉ាឡេស៊ីហើយនៅបន្តធ្វើការនៅទីនេះ គ្មានលទ្ធភាពរកបានអ្នកជួយដោះស្រាយ ដោយសារលែងមានក្រុមហ៊ុនតទៅទៀតហើយនោះ។ស្ថានទូតកម្ពុជានៅទីក្រុងគួឡាឡំពួបានផ្តល់ទីជំរកបណ្តោះអាសន្នដល់ជនជាតិខ្មែរបំរើការងារតាមផ្ទះ ដែលប្រឈមនឹងការធ្វើបាបនៅប្រទេសម៉ាឡេស៊ី តែស្ថានទូតគ្មាននិតិវិធីជាប្រព័ន្ធសំរាប់ជួយជនរងគ្រោះដោយការជួញដូរ តាមរយៈបេសកកម្មទូតរបស់ខ្លួននៅប្រទេសម៉ាឡេស៊ី ឬនៅប្រទេសដទៃទេ។

រដ្ឋាភិបាលកម្ពុជាតំរូវអោយជនរងគ្រោះជាជនបរទេសដែលត្រូវបានរកឃើញនៅកម្ពុជាត្រូវបាននាំទៅមាតុភូមិគេវិញ ហើយមិនបានផ្តល់ជំរើសផ្លូវច្បាប់ផ្សេងក្រៅពីការបញ្ជូនគេទេ ក្នុងករណីដែលគេជួប

ប្រទះការលំបាក ឬការធ្វើបាបនៅពេលទៅដល់ប្រទេសកំណើតរបស់គេវិញ។ គ្មានរបាយករណ៍និយាយថា ជនរងគ្រោះបានទទួលទណ្ឌកម្មចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តជាលទ្ធផលនៃការត្រូវបានគេជួញដូរទេ។ ការខិតខំអោយបានច្រើនថែមទៀតក្នុងការរកជនរងគ្រោះក្នុងចំណោមក្រុមមនុស្សងាយរងគ្រោះអាចជួយបញ្ចៀសកុំអោយជនរងគ្រោះទទួលការដាក់ទណ្ឌកម្ម។ អាជ្ញាធរ តាមសេចក្តីរាយការណ៍មក បានលើកទឹកចិត្តអោយជនរងគ្រោះចូលរួមក្នុងការស៊ើបអង្កេត និងការនាំជនប្រព្រឹត្តការជួញដូរមកកាត់ទោស ហើយជនរងគ្រោះជាបរទេសអាចស្នាក់នៅបណ្តោះអាសន្នដើម្បីចូលរួមក្នុងការស៊ើបអង្កេត និងការកាត់ទោស។ យ៉ាងណាក្តី ប្រព័ន្ធអនុវត្តច្បាប់ និងប្រព័ន្ធតុលាការទន់ខ្សោយ និងប្រកបដោយអំពើពុករលួយរបស់ប្រទេសកម្ពុជា ដំណើរការបណ្តឹងស៊ីពេលយូរ ការភ័យខ្លាចរបស់ជនរងគ្រោះចំពោះការសងសឹករួមផ្សំនឹងកង្វះការការពារសាក្សី ជំរើសក្នុងការស្នាក់នៅរយៈពេលយូរសំរាប់ជនរងគ្រោះបរទេស ឬកង្វះលទ្ធភាពចំពោះធនធាននៅតែធ្វើអោយជនរងគ្រោះមិនចង់ធ្វើសហប្រតិបត្តិការនៅក្នុងករណីនានា ដែលជាការបង្ករជាឧបសគ្គដល់លទ្ធភាពរបស់គេក្នុងការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់។ រដ្ឋាភិបាលមិនអនុវត្តនិតិវិធីអោយបានខ្ជាប់ខ្ជួនដើម្បីធានាផលប្រយោជន៍សំរាប់ជនរងគ្រោះឡើយ។ថ្វីបើបានកំណត់បទដ្ឋានដែលតំរូវអោយអ្នកផ្តល់សេវារួមទាំងនគរបាលផង ធានាអោយមានកន្លែងសុវត្ថិភាពមួយសំរាប់ធ្វើការសំភាសន៍ជាមួយជនរងគ្រោះក្តី តែជាធម្មតា រដ្ឋាភិបាលខ្វះបរិក្ខា និងកន្លែងការិយាល័យចាំបាច់សំរាប់ធ្វើការសំភាសន៍ជនរងគ្រោះ ហើយជាញឹកញាប់ ជនរងគ្រោះ និងជនល្មើសត្រូវបានសំភាសន៍នៅកន្លែងតែមួយ។ ជាគោលការណ៍ ជនរងគ្រោះអាចទទួលសំណង តែជាក់ស្តែង ករណីសងនេះមិនសូវមានធ្វើច្រើនទេ ដោយសារច្បាប់តំរូវអោយទូទាត់សងតែនៅពេលជនល្មើសចេញពីពន្ធនាគារតែប៉ុណ្ណោះ បន្ទាប់ពីបំពេញទោសហើយ។

**ការបង្ការ (Prevention)**

រដ្ឋាភិបាលកម្ពុជាបានបន្តការខិតខំដើម្បីការពារកុំអោយមានការជួញដូរមនុស្ស ក្នុងអំឡុងពេលនៃរបាយការណ៍នេះ។គណៈកម្មាធិការជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ការរត់ពន្ធ និងការ

កេងប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្ម និងលេខាធិការដ្ឋានរបស់គណកម្មាធិការនេះបានបន្តដឹកនាំការខិតខំប្រឆាំងការជួញដូររបស់ប្រទេសកម្ពុជា ដូចជាតាមរយៈការចេញរបាយការណ៍ប្រចាំឆ្នាំស្តីពីការខិតខំក្នុងការប្រឆាំងនឹងការជួញដូរមនុស្សរបស់រដ្ឋាភិបាល និងតាមរយៈការធ្វើការអនុវត្តផែនការសកម្មភាពប្រឆាំងការជួញដូររបស់គណកម្មាធិការ។ គណកម្មាធិការ ក្រុមការងារ និងសាខាតាមខេត្តរបស់ខ្លួនបានធ្វើការប្រជុំសរុបចំនួន ១៧៦ ដង នៅក្នុងឆ្នាំនៃរបាយការណ៍។ នៅក្នុងការខិតខំដើម្បីដោះស្រាយអោយបានល្អនូវបញ្ហានៃការកេងប្រវ័ញ្ចលើពលករខ្មែរនៅបរទេស រដ្ឋាភិបាលបានបង្កើតក្រុមការងារសំរាប់អ្នកធ្វើចំណាកស្រុកនៅក្នុងគណកម្មាធិការប្រឆាំងការជួញដូររបស់ខ្លួន ដែលរួមមានតំណាងរបស់រដ្ឋាភិបាល ក្រុមហ៊ុនជ្រើសរើសពលករ និងសង្គមស៊ីវិល។ ថ្វីបើក្រុមនេះបានបញ្ជូនគណប្រតិភូមួយទៅកាន់ប្រទេសម៉ាឡេស៊ីកាលពីខែធ្នូ ឆ្នាំ ២០១២ ក្តី តែប្រទេសទាំងពីរមិនបានអនុម័តលើអនុស្សារណៈយោគយល់គ្នាទ្វេភាគីស្តីពីការធ្វើចំណាកស្រុករបស់ពលករបំរើតាមផ្ទះរបស់កម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ីទេ។ រដ្ឋាភិបាលមិនបានកែលំអឬពង្រឹងការអនុវត្តលើអនុក្រឹតលេខ ១៩០ ដែលត្រូវបានអនុម័តយល់ព្រមនៅក្នុងឆ្នាំរបាយការណ៍មុន ហើយដែលគ្រប់គ្រងលើសកម្មភាពរបស់បណ្តាក្រុមហ៊ុនដែលជ្រើសរើសជនជាតិខ្មែរអោយទៅធ្វើការនៅបរទេសទេ ថ្វីបើខ្លួនបានដាក់ទោសលើបុគ្គលិកចំនួន ៤ រូបរបស់ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណមួយ ពីបទជួញដូរពលកម្មក្តី។ ជារួម បទបញ្ញាតិរបស់ប្រទេសកម្ពុជាដែលគ្រប់គ្រងលើការជ្រើសរើស ការរកការងារអោយ និងការការពារពលករចំណាកស្រុកនៅបរទេស នៅខ្សោយនៅឡើយ។ គោលនយោបាយទាំងនេះខ្វះការបែងចែកច្បាស់លាស់រវាងការទទួលខុសត្រូវរបស់ទីភ្នាក់ងារជ្រើសរើសពលករ និងអាជ្ញាធររដ្ឋាភិបាល នៅក្នុងអំឡុងពេលនៃដំណើរការជ្រើសរើសពលករ ហើយមិនបានបញ្ជាក់លំអិតពីការតាមដាន ឬការគ្រប់គ្រងសមស្របលើទីភ្នាក់ងារនានា ដើម្បីជៀសវាងការរំលោភ ការពារកុំអោយមានអំពើពុករលួយ ឬកំណត់ទោសព្រហ្មទណ្ឌឡើយ។ បញ្ហាដូចជាការដកហូតលិខិតឆ្លងដែនទុក និងការធ្វើអោយជាប់ទាសភាពបំណុលមិនត្រូវបានដោះស្រាយបានគ្រប់គ្រាន់ទេ។

ម្ចាស់អំណោយបរទេស និងម្ចាស់អំណោយក្នុងស្រុកបានផ្តល់ការឧបត្ថម្ភដល់រដ្ឋាភិបាលអោយធ្វើយុទ្ធនាការអប់រំ និងលើកកំពស់ការយល់ដឹង។ រដ្ឋាភិបាលបានចែកស៊ីឌី និងវីស៊ីឌីដែលមានខ្លឹមសារអប់រំប្រជាជនពីគ្រោះថ្នាក់នៃការជួញដូរដែលអាចកើតមានតាមរយៈការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។ មន្ត្រីក្រសួងកិច្ចការនារីបានរៀបចំពិធីលើកកំពស់ការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ហើយបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយ ដើម្បីរៀបចំការពិភាក្សាតុមូលផ្សាយតាមទូរទស្សន៍មួយស្តីពីរឿងនេះ។ ជាថ្មីម្តងទៀត រដ្ឋាភិបាលបានរៀបចំពិធីដើម្បីរំលឹកដល់ទិវាលើកកំពស់ការយល់ដឹងប្រឆាំងការជួញដូរ នៅខែធ្នូ បានរៀបចំយុទ្ធនាការលើកកំពស់ការយល់ដឹងនៅតាមខេត្តចំនួន ៤ ហើយបានរៀបចំការដង្ហែរក្បួនមួយនៅតាមព្រំដែនកម្ពុជា ថៃ ដោយមានអ្នកចូលរួមចំនួន ១៦០០ នាក់មកពីរដ្ឋាភិបាល និងសង្គមស៊ីវិល។ ក្រសួងទេសចរណ៍បានរក្សាការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើផ្ទាំងប៉ាណូ ការឃោសនាតាមទស្សនាវដ្តី និងក្រដាសថែងអោយ ដើម្បីកាត់បន្ថយតំរូវការលើជំនួញផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ ថ្វីបើការខិតខំទាំងនេះសំដៅលើទេសចរផ្លូវភេទបរទេស ជាជាងមនុស្សនៅក្នុងប្រទេស ដែលជាប្រភពសំខាន់នៃតំរូវការលើជំនួញផ្លូវភេទលើកុមារក្តី។

អាជ្ញាធរបានដាក់ទោសលើជនបរទេសចំនួន ៣ នាក់ដែលបានធ្វើទេសចរណ៍ផ្លូវភេទលើកុមារ ក្នុងឆ្នាំនៃរបាយការណ៍នេះ ហើយករណីចំនួន ២ កំពុងឆ្លងសវនាការ។ ចំណាត់ការរបស់រដ្ឋាភិបាលក្នុងករណីអាណាចារលើកុមារបានធ្វើអោយប៉ះពាល់ដល់ជំនឿលើការខិតខំរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ។រដ្ឋាភិបាលបានបណ្តេញចេញនូវជនបរទេសម្នាក់ដែលបានប្រព្រឹត្តអំពើអាណាចារលើកុមារ ដែលត្រូវបានតុលាការរកឃើញថាមានទោស ហើយជននោះទទួលបានការលើកលែងទោស និងត្រូវបានដោះលែងពីពន្ធនាគារមុនកាលកំណត់ នៅក្នុងអំឡុងពេលនៃរបាយការណ៍លើកមុន អោយទៅប្រទេសកូរ៉េខាងត្បូង បន្ទាប់ពីអង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិបានធ្វើការតស៊ូមតិជាច្រើន។ នៅពេលក្រោយមក ជននោះត្រូវបាននាំអោយទៅប្រឈមនឹងការចោទប្រកាន់ពីបទប្រព្រឹត្តអំពើ

អាណាចារ្យលើកុមារ នៅប្រទេសរុស្ស៊ី។ នៅខែធ្នូ ឆ្នាំ ២០១២ រដ្ឋាភិបាលបានបន្ធូបន្ថយការចោទប្រកាន់ប្រឆាំងនឹងជនជាតិអូស្ត្រាលីម្នាក់ដែលតុលាការបានរកឃើញថាបានប្រព្រឹត្តអំពើអាណាចារលើកុមារ ហើយបានដោះលែងជននោះពីពន្ធនាគារដោយគ្មានបានស៊ើបអង្កេតលើការអះអាងថា មេធាវីរបស់ជននោះបានសូកប៉ាន់គ្រួសាររបស់ជនរងគ្រោះ ដើម្បីអោយជនរងគ្រោះប្តូរចំលើយជាកសិណ។ ជនប្រព្រឹត្តអំពើអាណាចារ្យលើកុមារជាច្រើនដែលត្រូវបានតុលាការរកឃើញថាមានទោស ស្ថិតក្នុងចំណោមជនល្មើសចំនួន ៤១២ នាក់ ដែលទទួលបានការលើកលែងទោស កាលពីខែកុម្ភៈ ឆ្នាំ ២០១៣ ជាផ្នែកមួយនៃពិធីបុណ្យសពអតីតព្រះមហាក្សត្រខ្មែរ។ មន្ត្រីកម្ពុជាចំនួន ៥ នាក់បានឆ្លើយជាកសិណនៅសហរដ្ឋអាមេរិក ក្នុងការកាត់ទោសជនប្រព្រឹត្តអំពើអាណាចារលើកុមារ ដែលត្រូវបានចោទប្រកាន់ពីបទកេងប្រវ័ញ្ចលើកុមារ នៅប្រទេសកម្ពុជា។ នៅក្នុងការខិតខំដើម្បីបន្ថយតំរូវការលើការរកស៊ីផ្លូវភេទលើកុមារ រដ្ឋាភិបាលបានបន្តការឆ្មក់របស់នគរបាលនៅតាមផ្ទះបន។ ថ្វីបើគ្មានសេចក្តីរាយការណ៍មកថា ជនរងគ្រោះដែលត្រូវបានរកឃើញត្រូវបានដាក់ទណ្ឌកម្មទៅលើចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តជាលទ្ធផលនៃការត្រូវបានគេជួញដូរក្តី តែការខិតខំអោយបានច្រើនដើម្បីកំណត់ជនរងគ្រោះអោយបានឆាប់នៅក្នុងចំណោមក្រុមងាយរងគ្រោះ អាចជួយបញ្ចៀសជនរងគ្រោះមិនអោយទទួលទណ្ឌកម្មក្នុងនាមជាអ្នករំលោភច្បាប់។ គណកម្មាធិការប្រឆាំងការជួញដូរបានបើកវគ្គបង្រៀនដល់ទាហាន ស្តីពីការជួញដូរមនុស្ស នៅមុនពេលពួកគេត្រូវបានបញ្ជូនអោយទៅបំពេញបេសកកម្មថែរក្សាសន្តិភាពនៅបរទេស។